# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង

ស្តីពីការព្យួរកិច្ចសន្យាការងាររវាង **តំណាងកម្មករនិយោជិត និងសណ្ឋាគារ អង្គរមិរ៉ាខល រីហ្សត និងស្ប៉ា** កាលពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង០៨ និង ០០នាទី មានការប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារនៅក្នុងសណ្ឋាគារ អង្គរ មិរ៉ាខល រីហ្សត និងស្ប៉ា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៦ ភូមិកសិកម្ម សង្កាត់ស្រង៉ែ ស្រុកសៀមរាប ខេត្តសៀមរាប។

<u>**សមាសភាពដែលចូលរួមក្នុងអង្គប្រជុំមាន៖**</u>

| **ក/ភាគីនិយោជក (តំណាងអោយក្រុមហ៊ុន)៖** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
|---|---|---|
| ឈ្មោះ សាន្ត ពិសិត | ប្រធានគ្រប់គ្រងផ្នែកធនធានមនុស្ស | 086 379 880 |

| **ខ/ភាគីកម្មករនិយោជិត (តំណាងអោយកម្មករ)** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
|---|---|---|
| ឈ្មោះ ឆែម ឌឹម | ប្រតិភូបុគ្គលិក | 016 601 004 |

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធនឹងការព្យួរកិច្ចសន្យាការងារ សមស្របតាមសេចក្តីណែនាំលេខ: ០៤៥/២០កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រប់ភាគីទាំងសងខាងបានឯកភាពយល់ព្រមបន្តព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតទាំងអស់ចំនួន ១៤៣នាក់ (ស្រី ៧៤នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១៥៥នាក់ (ស្រី ៧៨នាក់) ក្នុងរយៈពេល ៦១ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ដោយទទួលបានប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន ៤០ដុល្លាអាមេរិកក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ។ ដោយឡែក សម្រាប់សណ្ឋាគារ អង្គរមិរ៉ាខល រីហ្សត និងស្ប៉ា ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់ប្រាក់ឧបត្ថមបន្ថែមដល់បុគ្គលិកក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះឡើយ ដោយសារខាងសណ្ឋាគារទទួលរងផលប៉ះពាល់ខ្លាំងពីជម្ងឺ Covid-19 និងបានបាត់បង់ប្រាក់ចំណូល។

ការពិភាក្សានេះត្រូវបានបញ្ចប់នៅវេលាម៉ោង ៩ និង ៣០នាទី នាថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ ដោយមានចុះហត្ថលេខាព្រមព្រៀងពីតំណាងទាំងពីរដែលអាចយកជាការបានចំពោះមុខច្បាប់។

កិច្ចព្រមព្រៀងខាងលើបង្ហាញពីព័ត៌មានពិត និងត្រឹមត្រូវរវាងភាគីទាំងសងខាងដោយបានចុះហត្ថលេខាដូចខាងក្រោម៖

| **ភាគីតំណាងឱ្យនិយោជក** | **ភាគីតំណាងឱ្យកម្មករនិយោជិត** |
|---|---|
| **ហត្ថលេខា/ស្នាមមេដៃ** | **ហត្ថលេខា/ស្នាមមេដៃ** |
| Angkor Miracle Resort & Spa<br>Human Resource<br>សាន្ត ពិសិត | ឆែម ឌឹម |